ការអំពាវនាវសម្រាប់រកភស្តុតាងដើម្បីបកអាក្រាត ADB រយៈពេល ៥០ ឆ្នាំនៅក្នុងតំបន់អាស៊ី

វេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីធនាគារអភិវឌ្ឍន៍អាស៊ី (ដែលគេស្គាល់ផងដែរថាជា "វេទិកា") គឺជាបណ្តាញឯករាជ្យនៃអង្គការសង្គមស៊ីវិលនៃអង្គការថ្នាក់មូលដ្ឋាន ចលនាសង្គម និងសហគមន៍ដែលរងផលប៉ះពាល់នៅទូទាំងអាស៊ីខាងត្បូង អាស៊ីអាគ្នេយ៍ អាស៊ីកណ្តាល និងការប្រជុំរបស់បក្សនយោបាយនៅក្នុងប្រទេសអូស្ត្រាលី អឺរ៉ុប និង សហរដ្ឋអាមេរិក ដែលដើរតួជាអង្គការឃ្លាំមើលលើគម្រោង និងគោលនយោបាយទាំងអស់របស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ចាប់តាំងពីឆ្នាំ ១៩៩២។

យើងបានឃើញផ្ទាល់ភ្នែកនូវភាពក្រីក្រលំបាកតោកយ៉ាក់ ភាពគ្មានការងារធ្វើ និងការបាត់បង់នៃការចិញ្ចឹមជីវិត ចលាចលសង្គម និងការរំលោភសិទ្ធិមនុស្សត្រូវបាននាំយកមកដោយកម្មវិធី និងគម្រោងផ្សេងៗរបស់ ADB ដែលត្រូវបានជំរុញដោយមូលធនឯកជនក្នុងការត្រួតត្រាលើអ្វីដែលពីមុនជាកម្មសិទ្ធិសាធារណៈ។ គម្រោងបង្ហូរទឹក KJDRP នៅប្រទេសបង់ក្លាដែស គម្រោងទំនប់វារីអគ្គិសនី Nam Theun ២ នៅក្នុងប្រទេសឡាវ ការធ្វើអាជីវកម្មរ៉ែពីក្រុមហ៊ុន Marcopper នៅប្រទេសហ្វីលីពីន រោងចក្រត្បូងថ្មរបស់ក្រុមហ៊ុន Tata Mundra នៅក្នុងប្រទេសឥណ្ឌា កម្មវិធីវិនិយោគប្រកបដោយចីរភាពក្នុងការអភិវឌ្ឍន៍ទីក្រុងនៅក្នុងប្រទេសអាមេនី គម្រោងស្តារផ្លូវដែកនៅប្រទេសកម្ពុជា - ហើយក្នុងចំណោមអ្នកទាំងនោះផងដែរ - ពួកគាត់ទាំងអស់ ទទួលរងផលប៉ះពាល់ពីការអន្តរាគមន៍របស់ធនាគារអភិវឌ្ឍន៍អាស៊ីគឺពោរពេញទៅដោយហានិភ័យទៅដល់ប្រជាពលរដ្ឋដែលបាត់បង់ឱកាស និងជនងាយរងគ្រោះទាំងសេដ្ឋកិច្ច និងបរិស្ថាន ក៏ប៉ុន្តែធនាគារនេះនៅតែបន្តដើរតាមផ្លូវនេះហើយមានកម្រិតកាន់តែខ្លាំងឡើង។

ធនាគារ ADB បានគម្រប់ខួប ៥០ឆ្នាំ នៃប្រតិបត្តិការរបស់ខ្លួនក្នុងតំបន់អាស៊ី ដែល ADB មានអភ័យឯកសិទ្ធិដែលត្រូវបានព្រមព្រៀងដោយច្បាប់អន្តរជាតិឱ្យធនាគារអភិវឌ្ឍន៍អាស៊ីជាអង្គការអន្តរជាតិនៅក្នុងអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិនៃអនុសញ្ញាទីក្រុងវីយែន និងទីភ្នាក់ងារឯកទេសផ្សេងៗ។ បុព្វសិទ្ធិនេះផងដែរត្រូវបានអះអាងដោយធនាគារអភិវឌ្ឍន៍អាស៊ីនៅក្នុងធម្មនុញ្ញរបស់ខ្លួន និងកិច្ចព្រមព្រៀងនៅទីស្នាក់

NGO Forum on ADB

ការកណ្តាលរបស់ខ្លួនជាមួយនឹងរដ្ឋាភិបាលដែលខ្ចីប្រាក់របស់ធនាគារដើម្បីការពារធនាគារពីការប្តឹងពីរដ្ឋាភិបាល ឬដោយភ្នាក់ងារ ឬភាពជាឧបករណ៍របស់ខ្លួនណាមួយ ឬដោយអង្គភាព ឬបុគ្គលដែលស្វែងរកបណ្តឹងនៅខាងក្រៅនៃយន្តការសារទុក្ខផ្ទៃក្នុងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី វាមានប្រសិទ្ធិភាព ដល់ទីភ្នាក់ងាររបស់ខ្លួនរួចផុតពីគណនេយ្យភាពយ៉ាងពេញលេញ។

ដើម្បីបកអាក្រាតធនាគារ ADB យើងត្រូវការភស្តុតាង!

ដើម្បីប្រជែងអភ័យឯកសិទ្ធិរបស់ ADB យើងត្រូវការភស្តុតាង!

វិសមភាពរបស់បុព្វសិទ្ធិនៃអភ័យឯកសិទ្ធផ្លូវច្បាប់ បានអនុញ្ញាតឱ្យធនាគារអភិវឌ្ឍន៍អាស៊ីធ្វើការជាមួយនឹងនិទណ្ឌភាពរបស់ខ្លួនដើម្បីប្រឆាំងនឹងបរិស្ថាន សិទ្ធិមនុស្ស និងការអភិវឌ្ឍខ្លួនឯង។ វិធាននៃច្បាប់នេះផងដែរត្រូវតែអនុវត្តទៅធនាគារអភិវឌ្ឍន៍ពហុភាគី ប្រសិនបើយើងចង់បំពេញតាមការទាមទារសិទ្ធិមនុស្ស និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព។

វេទិកាដែលមានបទពិសោធន៍ជាច្រើនឆ្នាំក្នុងការចូលរួមជួយដាស់តឿនធនាគារអភិវឌ្ឍន៍អាស៊ីបង្ហាញនូវភាពវិជ្ជមានក្នុងភាសាគោលនយោបាយនានា ប៉ុន្តែមានឥទ្ធិពលតិចតួចនៅក្នុងប្រតិបត្តិការរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។

វេទិកានេះបានយល់ឃើញថា វាជាការចាំបាច់ដើម្បីបង្គាប់អោយធនាគារអភិវឌ្ឍន៍អាស៊ី មានគណនេយ្យភាព ព្រោះវាមិនត្រឹមតែសម្រាប់ការយល់ដឹងពីផលប៉ះពាល់នៃគម្រោងរបស់ខ្លួននោះទេ តែសម្រាប់ការយល់ដឹងពីការផ្តល់ហិរញ្ញប្បទានដល់សិទ្ធិរំលោភលើដំណើរការអភិវឌ្ឍនានា។ ដំណើរការនេះគឺអាចធ្វើទៅបាន ប្រសិនបើធនាគារអភិវឌ្ឍន៍អាស៊ីអាចមានគណនេយ្យភាពនៅខាងក្រៅនៃយន្តការបណ្តឹងរបស់ខ្លួន និងទទួលខុសត្រូវនៅក្រោមច្បាប់ជាតិ និងអន្តរជាតិនានា។

NGO Forum on ADB

ឥឡូវនេះដល់ពេលដើម្បីប្រជែងអភ័យឯកសិទ្ធិរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។

នៅគម្រប់ខួបទី ៥០ឆ្នាំ នៃធនាគារអភិវឌ្ឍន៍អាស៊ី យើងមានបំណងបកអាក្រាតនូវកំណត់ត្រានៃដំណើរការបំផ្លិចបំផ្លាញរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។

យើងកំពុងបញ្ជូនការអំពាវនាវនេះទៅគ្រប់គ្នា ដើម្បីអោយពួកគេនាំមកនូវ ការសិក្សាស្រាវជ្រាវ និងរឿងរ៉ាវរបស់ពួកគេស្តីពីធនាគារអភិវឌ្ឍន៍អាស៊ីដែលទាក់ទងនឹងអ្វីដែលធនាគារនេះគួរតែទទួលខុសត្រូវក្នុងចំណោមប្រធានបទទាំងប្រាំនេះ៖ បំណុល ការបំផ្លិចបំផ្លាញ ភាពក្រខ្សត់ ការភៀសខ្លួន និងគម្លាតខុសគ្នា។

ប្រសិនបើអ្នក ឬអង្គការរបស់អ្នកចង់ផ្តល់ជូននូវការស្រាវជ្រាវ ឯកសារនៃសហគមន៍ដែលរងផលប៉ះពាល់ពីគម្រោង ក្នុងទ្រង់ទ្រាយជា សក្ខីភាព អត្ថបទ វីដេអូ និងរូបភាព សូមផ្ញើវាមក ដើម្បីរួមចំណែកដល់រលកថ្មីនៃភាពយុត្តិធម៌។

យើងមិនគួររង់ចាំ ៥០ ឆ្នាំទៀតទេ។

នេះគឺជាការអំពាវនាវសម្រាប់រកភស្តុតាង និងសក្ខីភាពសម្រាប់បកអាក្រាតធនាគារអភិវឌ្ឍន៍អាស៊ី។ សូមផ្ញើសំណួរ និងដាក់ស្នើជាមួយនឹងសេចក្តីណែនាំជាសង្ខេបទៅកាន់:

អ៊ីម៉ែល: evidence@forum-adb.org
សំបុត្រ: ភស្តុតាង
វេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីធនាគារអភិវឌ្ឍន៍អាស៊ី
ផ្ទះលេខ ៨៥A ផ្លូវ Masikap
ខេត្ត Diliman ប្រទេសហ្វីលីពីន
១១០៣